**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
អគ្គនាយកដ្ឋានកសិកម្ម
នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម

# គំរូរបាយការណ៍ប្រចាំឆ្នាំ

2015

អនុវត្តចាប់ពីថ្ងៃទី01 ខែមករា ឆ្នាំ2015 ដល់ថ្ងៃទី 31 ខែធ្នូ ឆ្នាំ2015

# សហគមន៍កសិកម្ម
# អង្គររុងរឿង

រៀបចំដោយៈ គម្រោងបង្កើតសហគមន៍កសិកម្មគំរូដែលតម្រង់ទិសដៅទៅលើការធ្វើជំនួញ (BPAC)

# មាតិកា

1. **សកម្មភាពសំខាន់ៗរបស់សហគមន៍កសិកម្ម** ........ 1
2. **ការងាររដ្ឋបាល** ........ 2
2.1 ការប្រជុំ ........ 2
3. **រចនាសម្ព័ន្ធគ្រប់គ្រងរបស់សហគមន៍កសិកម្ម** ........ 3
3.1 ព័ត៌មានសមាជិកសហគមន៍កសិកម្ម ........ 3
3.2 ព័ត៌មានថ្នាក់ដឹកនាំ (ក្រុមប្រឹក្សាភិបាលនិងគណៈកម្មាធិការត្រួតពិនិត្យ) ........ 4
3.3 បុគ្គលិកជួលពីខាងក្រៅ ........ 4
3.4 ព័ត៌មានភាគហ៊ុន ........ 4
4. **សកម្មភាពអប់រំរបស់សហគមន៍កសិកម្ម** ........ 5
4.1 ក្រុមប្រឹក្សាភិបាល ........ 5
4.2 គណៈកម្មាធិការត្រួតពិនិត្យ ........ 5
4.3 សមាជិកសហគមន៍កសិកម្ម ........ 5
5. **ទ្រព្យសម្បត្តិសហគមន៍កសិកម្ម** ........ 6
5.1 ទ្រព្យសម្បត្តិ ........ 6
6. **មុខរបរ ឬ មុខជំនួញរបស់សហគមន៍កសិកម្ម** ........ 6
6.1 មុខរបរឥណទាន ........ 6
6.2 មុខរបរផ្គត់ផ្គង់ ........ 8
6.3 មុខរបរទីផ្សារ ........ 9
6.4 មុខរបរសេវាប្រើប្រាស់រួមគ្នា ........ 11
6.5 មុខរបរផ្សេងៗ ........ 11
7. **របាយការណ៍លទ្ធផល " ចំណេញ ឬ ( ខាត )"** ........ 12
8. **ការបែងចែកប្រាក់ចំណេញ** ........ 13
9. **តារាងតុល្យការ** ........ 15
10. **របាយការណ៍គណៈកម្មាធិការត្រួតពិនិត្យ** ........ 17
11. **កំណត់ហេតុមហាសន្និបាតប្រចាំឆ្នាំរបស់សហគមន៍កសិកម្ម** ........ 19

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# សហគមន៍កសិកម្មអង្គរុងរឿង

## របាយការណ៍ប្រចាំឆ្នាំ2015

### 1. សកម្មភាពសំខាន់ៗរបស់សហគមន៍កសិកម្ម

សហគមន៍កសិកម្មអង្គរុងរឿង បានបង្កើតនៅថ្ងៃទី23 ខែធ្នូ ឆ្នាំ2008 ដែលមានអាសយដ្ឋានស្ថិតនៅភូមិ "ក" ឃុំ "ខ" ស្រុក "គ" ខេត្ត "ឃ" ។

របាយការណ៍ប្រចាំឆ្នាំនេះ បានឆ្លុះបញ្ចាំងពីការគ្រប់គ្រងនិងការប្រកបមុខរបររយៈពេលពេញមួយឆ្នាំរបស់សហគមន៍កសិកម្មដោយគិតចាប់ពីថ្ងៃទី 01 ខែមករា ឆ្នាំ2015 ដល់ថ្ងៃទី31 ខែធ្នូ ឆ្នាំ2015។ នៅចុងឆ្នាំ2015នេះ សហគមន៍កសិកម្មអង្គរុងរឿងមានសមាជិកសរុបចំនួន120នាក់ ដែលក្នុងនោះមានស្រីចំនួន75នាក់ មានភាគហ៊ុនសរុបចំនួន1000 ហ៊ុន។ សហគមន៍កសិកម្ម អង្គរុងរឿង បានរកប្រាក់ចំណូលដុលសរុបពីមុខរបរទាំងអស់ ចំនួន 149,600,000 រៀល ពីមុខរបរទាំងអស់ចំនួន 4 ដូចខាងក្រោមគឺ៖

(ក)មុខរបរឥណទាន (ប្រាក់បញ្ញើសន្សំ ប្រាក់ផ្ញើធនាគារ ប្រាក់ឱ្យគេខ្ចី) ទទួលបានការប្រាក់សរុប ចំនួន 19,300,000 រៀល ពីការប្រាក់នៃប្រាក់ឱ្យសមាជិកនិងមិនមែនសមាជិកខ្ចី និងការប្រាក់នៃប្រាក់ផ្ញើរធនាគារ នៅក្នុងឆ្នាំ2015 ។

(ខ)មុខរបរផ្គត់ផ្គង់ (ទិញពីខាងក្រៅយកមកផ្គត់ផ្គង់ជូនសមាជិកសហគមន៍កសិកម្ម និងអ្នកខាងក្រៅ ដូចជាផ្គត់ផ្គង់ជីកសិកម្ម ជាដើម) បានរកប្រាក់ចំណូលដុលសរុប (មិនទាន់ដកថ្លៃដើម និងចំណាយផ្សេងៗ) ចំនួន 48,000,000 រៀល នៅក្នុងឆ្នាំ2015 ។

(គ)មុខរបរទីផ្សារ (ប្រមូលផលិតផលកសិកម្មដូចជាស្រូវ អង្ករ ពីសមាជិកយកទៅលក់នៅទីផ្សារ) បានរកប្រាក់ចំណូលដុលសរុប (មិនទាន់ដកថ្លៃដើម និងចំណាយផ្សេងៗ) ចំនួន 72,300,000 រៀល នៅក្នុងឆ្នាំ2015 ។

(ឃ)មុខរបរផ្តល់សេវាប្រើប្រាស់រួមគ្នា (ការជួលត្រាក់ទ័រ) បានរកប្រាក់ចំណូលដុលសរុប (មិនទាន់ដកចំណាយផ្សេងៗ) ចំនួន 10,000,000 រៀល ។

(ង)មុខរបរផ្សេងៗបានរកប្រាក់ចំណូលដុលសរុប (មិនទាន់ដកចំណាយផ្សេងៗ) ចំនួន……………………… រៀល នៅក្នុងឆ្នាំ2015។